អង្គរបុរី
សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណ ហុក-សាវណ្ណ
## ក្រោមប្រធានបទ ខ្មែរមានសីលធម៌ធ្លាក់ចុះ ហាក់ដូចជានៅ
## តែដើរតាមគន្លងខ្មោចប៉ុល-ពត ។

www.hoksavann.org

ថ្ងៃទី២២ វិច្ឆិកា ២០១១



ប្រទេសកម្ពុជាសព្វថ្ងៃនេះ គេទទួលស្គាល់ថា បានចំរើនលូតលាស់ក្នុងវិស័យខ្លះហើយ ដូចជាវិស័យហេដ្ឋារចនាសម្ពន្ធផ្លូវគមនាគមន៍ជាដើម ប៉ុន្តែការបំបាត់ភាពក្រីក្រនៃប្រជាពលរដ្ឋខ្មែរនៅជាអរិជ្ជមានខ្លាំងណាស់ ។ ជាពិសេសភាពហឹង្សា អសីលធម៌ ចេះតែកើតមាននៅប្រទេសកម្ពុជា មានហឹង្សាក្នុងចំណោមប្រជាពលរដ្ឋ និងហឹង្សានយោបាយ ។

ព្រះពុទ្ធបានចាត់ទុកសីលធម៌ជាគុណសម្បត្តិរបស់មនុស្សគ្រប់រូប ។ មនុស្សទោះបីមានឋានៈខ្ពស់ទាបជាងគ្នា មានកម្រឹតវិជ្ជា មានចំនួនទ្រព្យសម្បត្តិតិចច្រើនជាងគ្នាយ៉ាងណាក៏ដោយ បើគេប្រព្រឹត្តល្អដោយកាយវាចាចិត្ត គេជាមនុស្សខ្ពង់ខ្ពស់ថ្លៃថ្នូរ ។ ផ្ទុយទៅវិញ មនុស្សប្រភេទដដែលនេះ បើគេប្រព្រឹត្តអាក្រក់ដោយកាយវាចាចិត្ត គេជាមនុស្សថោកទាប ។ ដូច្នេះព្រះពុទ្ធបានចាត់មនុស្សខ្ពង់ខ្ពស់ថ្លៃថ្នូរ និងមនុស្សថោកទាប ដោយសារអំពើដែលគេប្រព្រឹត្តជាខ្នាតសំរាប់វាស់ មិនយកបុណ្យស័ក្តិទ្រព្យសម្បត្តិជាខ្នាតសំរាប់វាស់ឡើយ ។ ដូចនេះ ដើម្បីឲ្យប្រទេសកម្ពុជាបានសុខសន្តិភាព និងវឌ្ឍនភាព គប្បីខ្មែរគ្រប់ឋានៈ ទាំងប្រជាពលរដ្ឋ ទាំងអ្នករាជការ គប្បីបណ្តុះនូវគុណធម៌មានសីលធម៌ជាដើមឲ្យមានក្នុងខ្លួន ដោយជៀសវាងអំពើហឹង្សាគ្រប់យ៉ាង ទាំងហឹង្សាក្នុងគ្រួសារ ក្នុងសហគមន៍ ទាំងហឹង្សានយោបាយ ដែលភាសាផ្លូវលោកថា ត្រូវគោរពសិទ្ធិមនុស្ស ។

មានពលរដ្ឋខ្មែរខ្លះ បានប្រព្រឹត្តធ្វើអំពើចោរកម្ម លួចប្លន់ទ្រព្យសម្បត្តិអ្នកដទៃ មានខ្លះសម្លាប់ម្ចាស់ទ្រព្យទៀតផង ។ មានខ្លះលួចសម្លាប់គ្នាដោយចងកំហឹងពីរឿងអ្វីមួយ ។ បើក្នុងគ្រួសារវិញ មានប្តីខ្លះវាយធ្វើបាបប្រពន្ធ ដោយកម្លាំងទោសៈ ឬដោយស្រវឹងស្រា ។ មានបុរសខ្លះក្បត់ចិត្តភរិយា លួចមានស្រីដទៃទៀត រហូតចម្លងរោគអេដស៍ឲ្យដល់ប្រពន្ធខ្លួនទៀតផង ។ អំពើអសីលធម៌ទាំងនេះអាចជៀសវាងបានដោយពិចារណាថា អ្នកដទៃក៏ស្រឡាញ់ជីវិត ស្រឡាញ់ទ្រព្យសម្បត្តិ ស្រឡាញ់សេចក្តីសុខដូចខ្លួនដែរ ដូច្នេះមិនត្រូវបៀតបៀនធ្វើឲ្យគេមានទុក្ខឡើយ ។ មួយទៀត អំពើអាក្រក់នេះនឹងមានកម្មពៀរទៅមុខទៀត ហើយរដ្ឋចាប់បាននិងផ្តន្ទាទោសផង ។ បើជៀសវាងអំពើអាក្រក់ទាំងនេះបាន ឈ្មោះថាជាអ្នកមានសីលធម៌ ។

អ្នកប្រព្រឹត្តអំពើជួញដូរមនុស្ស ដោយនិយាយបោកបញ្ឆោតខ្មែរខ្លះ ឲ្យទៅធ្វើការយ៉ាងធូន់ បញ្ឆោតកុមារីខ្មែរឲ្យធ្វើជាស្រីពេស្យាចារ ជាអំពើអមនុស្សធម៌ធ្ងន់ណាស់ ។ អ្នកប្រកបមុខរបរទុច្ចរិតនេះ ត្រូវតែបញ្ឈប់ជាបន្ទាន់ ព្រោះអំពើនេះតាមផ្លូវព្រះធម៌ ព្រះអង្គបានហាមកុំឲ្យពុទ្ធបរិស័ទរបស់ព្រះអង្គប្រព្រឹត្ត ព្រោះជាជំនួញបៀតបៀនមនុស្ស ជាជំនួយខុសប្រាសចាកសីលធម៌ ។ ជំនួញជួញដូរមនុស្ស មិនត្រឹមតែរដ្ឋខ្មែរទេដែលបានហាម គឺពិភពលោកទាំងមូលបានហាម ថែមទាំងបានអំពាវនាវឲ្យគ្រប់ប្រទេសទាំងអស់ព្រួតដៃគ្នា កំចាត់ហើយធ្វើទោសឲ្យបានធ្ងន់ ។ អ្នកប្រព្រឹត្តអំពើជួញដូរមនុស្សនេះអាចបញ្ឈប់ដោយពិចារណាថា បើគេយកកូនចៅខ្លួនទៅលក់ដូរវិញ តើទឹកចិត្តខ្លួនបែបណាដែរ ? ហើយអំពើនេះនាំឲ្យខូចកិត្តិយសជាតិផង ។ តាមអ្នកយកការណ៍អន្តរជាតិចោទថា អ្នកជួញដូរមនុស្សមានក្រុមប៉ូលិសនិងមន្ត្រីរាជការជាបង្អែកនៅពីក្រោយ មិនងាយកំចាត់បានទេ ។ អាចកំចាត់បានលុះត្រាតែចាប់អ្នកបង្អែកនោះមកកាត់ទោស ។ សមាជិកសភាសហរដ្ឋអាមេរិកម្នាក់បានស្នើឲ្យរដ្ឋសភាដាក់ប្រទេសកម្ពុជា ពីកម្រឹតទី២មកកម្រឹតទី៣ អំពីបញ្ហាជួញដូរមនុស្សនេះ ។ កម្រឹតទី៣ គឺកម្រឹតដ៏ខ្ពស់ មកពីរដ្ឋាភិបាលខ្មែរមិនយកចិត្តទុកដាក់ដោះស្រាយអំពើជួញដូរមនុស្សនេះ ។

អ្នកយកកុមារជាអនីតិជនទៅបំរើតាមផ្ទះ មានអ្នកខ្លះបានប្រព្រឹត្តអំពើអមនុស្សធម៌ធ្ងន់ណាស់ ។ កុមារាកុមារីក្រោមអាយុ១៨ឆ្នាំរាប់រយរាប់ពាន់នាក់ ដោយសារតែភាពក្រីក្រ ម្តាយឪពុក ឬឪពុកមាម្តាយមីង ជីដូនបានយកមកបំរើគេតាមផ្ទះនៅរាជធានីភ្នំពេញ និងនៅទីក្រុងនានានៃប្រទេសកម្ពុជា បានត្រូវអ្នកម្ចាស់ផ្ទះប្រើដូចជាខ្ញុំកញ្ជះដាច់ថ្លៃ ដោយឲ្យធ្វើការគ្មានពេលសំរាក គ្មានបានរៀនសូត្រ មានខ្លះត្រូវវាយដំ ។ កុមារីខ្លះបានត្រូវប្រុសម្ចាស់ផ្ទះរំលោភទៀតផង ។ បញ្ហាគួរឲ្យរន្ធត់មួយទៀត គឺស្ត្រីខ្មែរចំនួន៥០,០០០នាក់ ទៅធ្វើការនៅប្រទេសម៉ាឡេស៊ី ជាប្រទេសកាន់សាសនាឥស្លាម បានត្រូវគេរំលោភសិទ្ធិការងារ ។ ក្នុងចំណោមស្ត្រីខ្មែរ៥០,០០០នាក់នោះ ចំនួន៣០,០០០នាក់ធ្វើការបំរើតាមផ្ទះ បានត្រូវម្ចាស់ផ្ទះឲ្យធ្វើការបំរើគេជាច្រើនម៉ោងក្នុងមួយថ្ងៃៗ ស្ទើរគ្មានពេលសំរាក ឲ្យចំណីអាហារមិនគ្រប់គ្រាន់ ។ ស្ត្រីខ្មែរខ្លះបានត្រូវវាយធ្វើបាប រហូតមានរំលោភផ្លូវភេទទៀតផង ។ ប្រាក់ខែមានចំនួនតិច ហើយត្រូវមេក្រុមហ៊ុនកាត់យកស្ទើរតែអស់ ។ តាមពត៌មានថា ស្ត្រីខ្មែរជាង១០នាក់បានត្រូវស្លាប់នៅប្រទេសម៉ាឡេស៊ី ដោយពុំបានស្រាវជ្រាវឲ្យដឹងថា ស្លាប់ដោយសារអ្វីទេ ។ ឯក្រុមហ៊ុនចំនួន៣៩ ដែលជ្រើសរើសពលករទៅធ្វើការនៅបរទេស មានទៅប្រទេសម៉ាឡេស៊ីជាដើមបានរំលោភច្បាប់ ដោយបន្លំដំឡើងអាយុស្ត្រីខ្មែរឲ្យគ្រប់២១ឆ្នាំ ដើម្បីឲ្យបានទៅធ្វើការនៅប្រទេសម៉ាឡេស៊ី បានបង្ខាំងស្ត្រីខ្មែរទុកដូចជាប់គុក ។ ស្ត្រីខ្មែរពីរបីនាក់បានស្លាប់ មានស្ត្រីខ្មែរម្នាក់បានលោតទម្លាក់ខ្លួនបាក់ជើងទាំងពីរ ។ សោកនាដកម្មបែបនេះកើតមាន ដោយក្រសួងការងារនៃរាជរដ្ឋាភិបាលខ្មែរពុំយកចិត្តទុកដាក់ដោះស្រាយ ។ ដំណោះស្រាយមានតែមួយ គឺប្តឹងក្រសួងការងារ និងប្តឹងក្រុមហ៊ុនទុច្ចរិតឲ្យតុលាការកាត់ទោស ។

# ហើង្យានយោបាយ

ពិភពលោកបានដឹងច្បាស់ហើយ អំពីអាជ្ញាធរខ្មែរបច្ចុប្បន្ននេះ បានដេញបាញ់ប្រជាពលរដ្ឋខ្លួន ដែលហ៊ានក្រោកតវ៉ាអំពីដីធ្លីរបស់ខ្លួន ដែលក្រុមហ៊ុនរួមដៃជាមួយអ្នកមានអំណាចរំលោភយក ។ ចំណែកព្រៃឈើមានព្រៃឡង់ជាដើម បានត្រូវក្រុមហ៊ុនដែលមានអ្នកអំណាចខ្មែរនៅពីក្រោយ បានកាប់ស្ទើរពាយអស់ពីស្រុកខ្មែរ ហើយនៅពេលដែលសហគមន៍ខ្មែរក្រោកឡើងការពារសម្បត្តិជាតិនេះ បែរជាអាជ្ញាធរខ្មែរចង់ដាក់ពាក្យប្តឹងអ្នកស្នេហាជាតិទាំងនោះទៅវិញ ។ ការធ្វើបាតុកម្មនិងកូដកម្មបានត្រូវគេវាយបង្ក្រាបហើយចាប់តំណាងអ្នកស្រុកកាត់ទោស ។ បើប្រជាពលរដ្ឋមានបញ្ហាអ្វី ត្រូវការតុលាការឲ្យជួយរកយុត្តិធម៌ឲ្យខ្លួន តុលាការគ្មានយុត្តិធម៌ គ្មានឯករាជ្យ ពុករលួយស៊ីសំណូក ប្រជាពលរដ្ឋក្រីក្រត្រូវតែចាញ់ក្តីព្រោះគ្មានប្រាក់សូក ។ អំពើពុករលួយបានស៊ីរូងផ្ទៃក្នុង ដូចឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំប្រទេសកម្ពុជាបានថ្លែងថា ខ្មែរត្រូវបាត់បង់ប្រាក់ពី៣០០ទៅ៥០០លានដុល្លារក្នុង១ឆ្នាំ ដោយអំពើពុករលួយ ។ អាចារ្យចុងពោលថា ចោរមានពីរយ៉ាង ចោរមួយជារាស្ត្រធម្មតាដូចលួចគោលួចក្របី ចោរនោះអាចឆាប់ចាប់បាន ចំណែកចោរមួយទៀតពិបាកចាប់ណាស់ គឺចោរអង្គុយកៅអីបានដល់អ្នករាជការ ។ សិក្ខាបទអទិន្នាទានជាសិក្ខាបទទីពីរនៃសីល៥ ព្រះពុទ្ធបានហាមកុំឲ្យមនុស្សលួចទ្រព្យសម្បត្តិអ្នកដទៃ និងទ្រព្យសម្បត្តិរបស់ជាតិ មានទោសធ្ងន់ជាងការលួចទ្រព្យឯកជន ព្រោះថាទ្រព្យសម្បត្តិជាតិជារបស់រួមរបស់ខ្មែរទាំង១៤លាននាក់ ដូចលួចកាប់ឈើរបស់ជាតិ រំលោភយកដីរបស់ជាតិដូចជារបស់គរុភ័ណ្ឌ ព្រះសង្ឃមិនអាចចែកគ្នាបានឡើយ ព្រោះជារបស់ព្រះសង្ឃទូទៅ ។

ច្បាប់ប្រឆាំងអំពើពុករលួយបានផ្តួចផ្តើមឡើងតាំងពីឆ្នាំ១៩៩៤ ដល់ថ្ងៃ១០និង១១ មីនា ២០១០ ទើបអនុម័ត ចំណាយពេលអស់១៦ឆ្នាំ ។ គណបក្សប្រឆាំងនិងសង្គមស៊ីវិលបានសុំពន្យារពេលប្រជុំ ដើម្បីមានពេលពិនិត្យច្បាប់នេះឲ្យបានម៉ត់ចត់ បានត្រូវគណបក្សកាន់អំណាចច្រានចោល ។ ១៦ឆ្នាំពន្យារពេលបាន សុំពន្យារពេលតែ៣អាទិត្យមិនអាចពន្យារបាន ប្រញាប់ណាស់ ។ គណបក្សប្រឆាំងបានពោលថា នៅពេលប្រជុំពួកគេបានដឹងជាមុនថា ទោះបីបញ្ចេញមតិល្អយ៉ាងណាក៏ដោយ ក៏គេមិនស្របតាមឡើយ ប៉ុន្តែត្រូវតែធ្វើដើម្បីបំពេញកិច្ចជាតំណាងរាស្ត្រ ។

យើងសង្កេតឃើញថា បន្ទាប់ពីលោកហុក-ឡុងឌីបានស្លាប់ដោយមិនប្រក្រតី និងលោកហេង-ពៅបានជាប់គុកមក អំពើលួចបាញ់សម្លាប់តាមផ្លូវនយោបាយបានអន់ថយ ដូចជាលួចបាញ់អ្នកសារពត៌មាន លួចបាញ់គណបក្សប្រឆាំង លួចបាញ់ប្រធានសហជីពកម្មករលោកជា-វិជ្ជាជាដើម ។ ម្នាក់ស្លាប់ ម្នាក់ជាប់គុក ហាក់ដូចជាបំបិទភស្តុតាង ព្រោះតាំងពីរនាក់នេះជាដៃស្តាំរបស់អ្នកកាន់អំណាចជាន់ខ្ពស់ ។ ឥឡូវនេះ គេប្រើមធ្យោបាយថ្មីវិញ គឺប្រើតុលាការជាឧបករណ៍ ។ គេដឹងថា តុលាការខ្មែរនៅក្រោមអំណាចរាជរដ្ឋាភិបាលខ្មែរ ។៚

* *

*